

# ឥទ្ធិពលការបោះបង្គោល និង ប្រអប់ជម្រកត្រីសិប្បនិម្មិត ការពារធនធានជលផល ក្នុងដែននេសាទសហគមន៍

## ករណីសិក្សា

## នៅឃុំជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង


សិក្សាស្រាវជ្រាវដោយ

- លោក ឃី អាន
- លោក ម៉ន ផល្លា
- លោក ធីរ សារឿម
- លោក លី ហេង

រៀបចំចងក្រងដោយ

លោក ឃី អាន



ឆ្នាំ ២០០៨



បង្គោលកំណត់ព្រំប្រទល់តំបន់ការពារធនធានជលផលសហគមន៍ជ្រោយប្រស់ដែលបានសាងសង់រួច




ការចូលរួមពីភាគីពាក់ព័ន្ធក្នុងការបោះប្រអប់ជម្រកត្រីសិប្បនិម្មិតនៅតំបន់សហគមន៍ជ្រោយប្រស់

## សិក្សាស្រាវជ្រាវដោយ

**លោក ឃី អាន**

ទីប្រឹក្សា NCDD នៃកម្មវិធីគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅ

**លោក ម៉ន ផល្លា**

មន្ត្រីបង្គោល NRML ផ្នែកអង្គភាពរដ្ឋបាលមូលដ្ឋាន នៃគណៈកម្មាធិការប្រតិបត្តិ

ខេត្តកោះកុង

**លោក ធីរ សារឿម**

មន្ត្រីបង្គោល NRML ផ្នែកអង្គភាពរដ្ឋបាលមូលដ្ឋាន នៃគណៈកម្មាធិការប្រតិបត្តិ

ខេត្តកោះកុង

**លោក លី ហេង**

មន្ត្រីបង្គោល NRML ផ្នែកអង្គភាពរដ្ឋបាលមូលដ្ឋាន នៃគណៈកម្មាធិការប្រតិបត្តិ

ខេត្តកោះកុង

## រៀបចំចងក្រងដោយ

**លោក ឃី អាន**

## ឧបត្ថម្ភគាំទ្រដោយ

គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

កម្មវិធីគ្រប់គ្រងធនធានធម្មជាតិ និង ជីវភាពរស់នៅ ផ្នែករដ្ឋបាលមូលដ្ឋាននៃ គ ប្រ

ខេត្តកោះកុង

ម្ចាស់ជំនួយ DANIDA/DFID

# អារម្ភកថា

ករណីសិក្សានេះ ត្រូវបានរៀបចំចងក្រងឡើង ដោយគម្រោងគ្រប់គ្រងធនធានធម្មជាតិ និង ការប្រកបរបរចិញ្ចឹមជីវិត ផ្នែករដ្ឋបាលមូលដ្ឋាន របស់គណៈកម្មាធិការប្រតិបត្តិ នៃ គ ជ វ វ ខេត្តកោះកុង ។ សារៈប្រយោជន៍ឯកសារនេះនឹងឆ្លុះបញ្ចាំងអំពីលទ្ធផល និងឥទ្ធិពលជាក់ស្តែង ពីការអនុវត្តន៍គម្រោងការបោះបង្គោល និង ប្រអប់ជម្រកត្រីសិប្បនិម្មិតនៅក្នុងដែននេសាទ សហគមន៍តំបន់ឆ្នេរឈូងជ្រោយប្រស់ ដែលជាបទពិសោធន៍ថ្មីសម្រាប់ខេត្តកោះកុង ចំពោះការគ្រប់គ្រងធនធានជលផលតំបន់ឆ្នេរ ដោយមានការចូលរួមសហការពីស្ថាប័នពាក់ព័ន្ធ និង សហគមន៍នេសាទឃុំជ្រោយប្រស់ ។ ករណីសិក្សានេះ ក៏ជាឱកាសមួយនៃការចែករំលែកនូវចំណេះដឹង និងបទពិសោធន៍ដល់បណ្តាស្ថាប័ន និង អ្នកពាក់ព័ន្ធនានា ចំពោះការចូលរួមអនុវត្តគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ ចំពោះការងារគ្រប់គ្រងធនធានធម្មជាតិ ពិសេសលើការគ្រប់គ្រងធនធានជលផលតំបន់ឆ្នេរ និង ការប្រកបរបរចិញ្ចឹមជីវិត នៅថ្នាក់មូលដ្ឋានប្រកបដោយចីរភាព ។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ បណ្តាអ្នកពាក់ព័ន្ធនានាដូចជាៈ ក្រុមប្រឹក្សាឃុំជ្រោយប្រស់ ក្រុមប្រឹក្សាឃុំកោះកាពិ ប៉ុស្តិ៍ប៉ូលីសរដ្ឋបាលឃុំជ្រោយប្រស់ សហគមន៍នេសាទឃុំជ្រោយប្រស់ សហគមន៍នេសាទឃុំកោះកាពិ ប្រជានេសាទឃុំជ្រោយប្រស់ និង ប្រជានេសាទឃុំកោះកាពិ ដែលបានចូលរួមក្នុងការចែករំលែក រាល់មតិយោបល់ និង ទស្សនៈផ្ទាល់ខ្លួន ជុំវិញការយល់ដឹងជាមួយបទពិសោធន៍ជាក់ស្តែង ចំពោះការបោះបង្គោល និង ប្រអប់ជំរកត្រីសិប្បនិម្មិតក្នុងតំបន់ឈូងជ្រោយប្រស់ ដែលញ៉ាំងឱ្យការរៀបចំចងក្រងករណីសិក្សានេះ អាចសំរេចបានលទ្ធផលជាស្ថាពរ ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តកោះកុង និង ទីប្រឹក្សាកម្មវិធី PSDD/NCDD ដែលបានជួយសំរបសំរួល គាំទ្រដល់មន្ត្រីផ្នែករដ្ឋបាលមូលដ្ឋាន ក្នុងការចុះសិក្សាស្រាវជ្រាវ និង សូមថ្លែងអំណរគុណ

ចំពោះម្ចាស់ជំនួយ DANIDA/DFID ដែលបានឧបត្ថម្ភផ្នែកថវិកា ចំពោះការអនុវត្តន៍គម្រោង NRML D & D ក្នុងខេត្តកោះកុង ក៏ដូចជាដំណើរការចុះសិក្សាស្រាវជ្រាវ និង រៀបចំករណីសិក្សានេះ ។

ជាទីបញ្ចប់ យើងខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ករណីសិក្សានេះនឹងត្រូវបានប្រើប្រាស់សម្រាប់ជាបទពិសោធន៍ និង ផលប្រយោជន៍ ចំពោះការអភិវឌ្ឍន៍នៅមូលដ្ឋានលើការគ្រប់គ្រងធនធានជលផល ដើម្បីឆ្លើយតបទៅនឹងការប្រកបរបរចិញ្ចឹមជីវភាពរស់នៅតាមមូលដ្ឋានដោយចីរភាព។

សូមអរគុណ

# មាតិកាអត្ថបទ


១-　សេចក្តីផ្តើម:...............................................................០១

២-　ប្រវត្តិ:........................................................................០២

៣-　សកម្មភាពអនុវត្តគម្រោង:.................................................០៤

៣.១-　ប្រភពថវិកា និង អ្នកចូលរួមគាំទ្រគម្រោង:...............................០៤

៣.២-　សកម្មភាពចាប់ផ្តើមដំណើរការគម្រោង:....................................០៥

៤-　លទ្ធផលសម្រេចបាន:........................................................០៧

៤.១-　ឥទ្ធិពលរបស់គំរោង:..........................................................០៧

៤.១.១-　ផលអវិជ្ជមានដែលកើតឡើង:..............................................០៧

៤.១.២-　ផលវិជ្ជមានដែលកើតឡើង:................................................១០

៤.២- ការប្រៀបធៀបភាពប្រែប្រួលក្នុងសហគមន៍នេសាទជ្រោយប្រស់មុន និង ក្រោយអនុវត្តគម្រោង:.............................................................១៦

៥-　ការសន្និដ្ឋាន:.................................................................១៩

៦-　អនុសាសន៍:....................................................................២០

# ឥទ្ធិពលការបោះបង្គោល និង ប្រអប់ជម្រកត្រីសិប្បនិម្មិត
# ការពារធនធានជលផល ក្នុងដែននេសាទសហគមន៍

## ១. សេចក្តីផ្តើម:

ការអនុវត្តន៏គម្រោងបោះបង្គោល និង ប្រអប់ជម្រកត្រីសិប្បនិម្មិតនេះ ជាមេរៀន និង បទពិសោធន៍ថ្មីសម្រាប់ ការគ្រប់គ្រងធនធានជលផលតំបន់ឆ្នេរ ដោយត្រូវបាន និង កំពុងអនុវត្តនៅក្នុងសហគមន៍នេសាទឃុំជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង ចាប់តាំងពីឆ្នាំ ២០០៥ រហូតមកដល់បច្ចុប្បន្ន។ ទាំងស្ថាប័នជលផល អាជ្ញាធរមូលដ្ឋាន ក៏ដូចជាក្រុមប្រឹក្សាឃុំ សហគមន៍ ប្រជាជននៅតាមមូលដ្ឋាន និង អ្នកពាក់ព័ន្ធនានាភាគច្រើនកំពុងមានជំនឿជឿជាក់ និងក្តីសង្ឃឹមថាការអនុវត្តន៏គម្រោងនេះនឹងជួយលើកកំពស់ដល់កិច្ចការពារ អភិរក្ស និង គ្រប់គ្រងធនធានជលផល ដើម្បីឆ្លើយតបទៅនឹងសេចក្តីតម្រូវការ ចំពោះជីវភាពរស់នៅរបស់ប្រជាជនតំបន់ឆ្នេរក្នុងខេត្តកោះកុង ដែលពឹងផ្អែកលើការធ្វើនេសាទឱ្យបានគង់វង្សយូរអង្វែង។ ប៉ុន្តែចំណេះដឹង និង បទពិសោធន៍ជុំវិញនៃការអនុវត្តន៏គម្រោងប្រភេទនេះ គឺសមត្ថភាពនៅមានកម្រិត ដោយអនុវត្តបណ្តើរ រៀនសូត្របណ្តើរ និង ពុំទាន់បានចងក្រងផ្សព្វផ្សាយ និង ចែករំលែកបទពិសោធន៍នេះឱ្យបានទូលំទូលាយ ដល់បណ្តាស្ថាប័ន និង អ្នកពាក់ព័ន្ធទាំងឡាយនៅឡើយ ។ ទោះបីជាយ៉ាងនេះក្តី បច្ចុប្បន្នគម្រោងប្រភេទដូចគ្នានេះ កំពុងត្រូវបានពង្រីកការអនុវត្តនៅតាមបណ្តាស្រុកផ្សេងៗទៀតនៅតាមតំបន់ឆ្នេរ ដូចជា: ស្រុកស្រែអំបិល ស្រុកបូទុមសាគរ ស្រុកគីរីសាគរ និង ស្រុកមណ្ឌលសីមាផងដែរ។

គោលបំណងករណីសិក្សាគឺ ផ្តោតសំខាន់ទៅលើលទ្ធផល និង ឥទ្ធិពលដែលបានស្តែងចេញពីការអនុវត្តគម្រោងការបោះបង្គោល និង ប្រអប់ជម្រកត្រីសិប្បនិម្មិត នៅក្នុងដែននេសាទសហគមន៍តំបន់ឆ្នេរឈូងជ្រោយប្រស់ ។ ការគ្រប់គ្រងធនធានជលផល ស្មៅសមុទ្រ និង ធានា

ស្ថេរភាពជីវភាពរស់នៅរបស់ប្រជាជនដែលពាក់ព័ន្ធនឹងតំបន់នេសាទឈូងសមុទ្រជ្រោយប្រស់ ដើម្បីទុកជាមេរៀន និង បទពិសោធន៍សម្រាប់ចែករំលែកដល់បណ្តាអ្នកពាក់ព័ន្ធនានា ។

ជាក្តីសង្ឃឹម ការអនុវត្តន៍គម្រោងនេះ អាចនឹងធ្វើឱ្យប្រសើរឡើងវិញ ចំពោះការគ្រប់គ្រងធនធានជលផល ព្រមទាំងជួយលើកកំពស់ដល់ការធ្វើនេសាទរបស់ប្រជានេសាទក្រីក្រ ក្នុងតំបន់ឆ្នេរនៃសហគមន៍នេសាទឃុំជ្រោយប្រស់ ។

## ២. ប្រវត្តិៈ

តំបន់ឈូងសមុទ្រជ្រោយប្រស់ ជាកន្លែងនៃទីប្រសព្វរវាងទឹកសាប មកពីតំបន់ដីគោក និង ទឹកប្រៃមកពីដែនសមុទ្រ បង្កើតបានជាប្រព័ន្ធអេកូឡូស៊ីធម្មជាតិដ៏អំណោយផល ចំពោះភាពសម្បូរនៃពពួកជីវចម្រុះតំបន់ឆ្នេរ ពិសេសធនធានជលផល និងស្មៅសមុទ្រ ។ ដោយសារលក្ខណៈសម្បូរបែបនៃធនធានជលផលក្នុងតំបន់ឈូងសមុទ្រជ្រោយប្រស់ ទើបតំបន់នេះបានក្លាយជាកន្លែងនេសាទយ៉ាងសំខាន់ របស់ប្រជាជនដែលរស់នៅតាមតំបន់ឆ្នេរ។

ជាទូទៅប្រជានេសាទតំបន់ឈូងជ្រោយប្រស់ មកពីៈ ឃុំជ្រោយប្រស់ និង ឃុំកោះកាពិ នៃស្រុកកោះកុង, ឃុំព្រែកខ្សាច់ នៃស្រុកគីរីសាគរ, ឃុំពាមក្រសោប និង ឃុំប៉ាក់ខ្លង នៃស្រុកមណ្ឌលសីមា, ឃុំដងទង់, ភូមិស្ទាច់ង៉ាម និង ភូមិ៤ នៃស្រុកស្មាច់មានជ័យ, ខ័ណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ...។ល។ សកម្មភាពនេសាទក្នុងតំបន់នេះ មានប្រើប្រាស់ប្រភេទឧបករណ៍នេសាទផ្សេងៗដូចជាៈ មងក្តាម លបក្តាម មងត្រី មងបង្គា ឈិបយន្ត (ទូកឌុន) អួនអូស, អួនខូវ ឈិបរុញដោយដៃ រនងសំបកខ្យងចាប់មឹក, មងព័ទ្ធដាក់ថ្នាំ....។ល។ ភាពអាណាធិបតេយ្យនៃការនេសាទ និងបទល្មើសនេសាទក្នុងតំបន់ឈូងសមុទ្រជ្រោយប្រស់ បានបង្កឱ្យកើតមានឡើងនូវបញ្ហាទំនាស់ និងជម្លោះនេសាទឥតឈប់ឈរ រវាងអ្នកនេសាទក្នុងឃុំ និង អ្នកនេសាទមកពីខាងក្រៅ រវាងអ្នកនេសាទប្រើប្រាស់ឧបករណ៍ខុសៗគ្នា ឬរវាងអ្នកនេសាទជាមួយសមត្ថកិច្ចពាក់ព័ន្ធ និង ទំនាស់រវាងសមត្ថកិច្ច និងសមត្ថកិច្ច ចំពោះ

ការគ្រប់គ្រង។ ល។ បញ្ហាជម្លោះទាំងនេះបានបង្កនូវភាពលំបាក និង ភាពស្មុគ្រស្មាញចំពោះការងារគ្រប់គ្រងធនធានជលផលក្នុងតំបន់ឈូងជ្រោយប្រស់ ។

ជាផលវិបាក ស្មៅសមុទ្រត្រូវបានទទួលរងនូវការខូចខាត ធនធានជលផលត្រូវបានថយចុះយ៉ាងឆាប់រហ័ស ទំហំនៃបញ្ហាទំនាស់នេសាទកាន់តែមានភាពតានតឹងឡើងជាលំដាប់ និង ពិបាកដោះស្រាយ ។ ប្រជានេសាទតូចតាច ភាគច្រើនត្រូវបានប្រឈមនឹងការខូចខាត ឬ បាត់បង់ឧបករណ៍នេសាទ ជាមួយនឹងការនេសាទបានផលដ៏តិចតួចសម្រាប់ការផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ ។



ទិដ្ឋភាពទូទៅនៃភូមិនេសាទជ្រោយប្រស់ ស្ថិតក្នុងតំបន់ឆ្នេរសមុទ្រឃុំជ្រោយប្រស់

ដើម្បីដោះស្រាយបញ្ហាខាងលើនេះ សហគមន៍នេសាទឃុំជ្រោយប្រស់ត្រូវបានបង្កើតឡើង និងបានចូលរួមសហការជាមួយក្រុមប្រឹក្សាឃុំ ប៉ូលីសប៉ុស្តិ៍រដ្ឋបាលឃុំ ការិយាល័យជលផលខេត្ត និងអ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀត ចំពោះការគ្រប់គ្រងធនធានជលផល ។ ដោយអនុវត្តវិធានការអប់រំ ផ្សព្វផ្សាយ សកម្មភាពល្បាត និងផាកពិន័យចំពោះបទល្មើសនេសាទបានប្រព្រឹត្តទៅជាបន្តបន្ទាប់ ។ ក៏ប៉ុន្តែប្រសិទ្ធិភាពនៃលទ្ធផលការងារទទួលបានចំពោះការគ្រប់គ្រងធនធានជលផលក្នុងតំបន់នេះមានកម្រិតទាបនៅឡើយ ។ បន្ទាប់មកគំនិតឯកភាពរួមមួយរវាងភាគីពាក់ព័ន្ធ បានឈានទៅដល់ការចាប់ផ្តើមអនុវត្ត

គម្រោងបោះបង្គោល និង ប្រអប់ជម្រកត្រីសិប្បនិម្មិតការពារធនធានជលផល ក្នុងតំបន់ជ្រោយប្រសក៏ត្រូវបានដំណើរការឡើង ក្នុងគោលបំណងដោះស្រាយបញ្ហានានា ដូចបានរៀបរាប់ខាងលើ ។

## ៣~ សកម្មភាពការអនុវត្តគម្រោង

### ៣.១~ ប្រភពថវិកា និង អ្នកចូលរួមគាំទ្រគម្រោង:

- ប្រភពថវិកាជានីដា របស់កម្មវិធីសិលា មានៈ ថវិកាអ៊ិនអរអ៊ីមបន្ថែមឃុំជ្រោយប្រស់ ( ឆ្នាំ ២០០៥- ២០០៦) ថវិកាវិនិយោគខេត្ត ( ឆ្នាំ ២០០៥-២០០៦), និង ថវិកាស្រុកសាកល្បងកោះកុង ឆ្នាំ ២០០៦
- ប្រភពថវិកាជានីដា/ដេហ្វីត របស់ គ ជ វ វ ឆ្នាំ ២០០៧-២០០៨ មានៈ ថវិកាអ៊ិនអរអ៊ីមបន្ថែមឃុំ ជ្រោយប្រស់ និង ថវិកាស្រុកសាកល្បងកោះកុង
- ប្រភពថវិកា UNDP/GEF/SGP ( ឆ្នាំ ២០០៦ -២០០៧)
- ការគាំទ្រផ្នែកផ្លូវច្បាប់ និង បច្ចេកទេស (ពីអាជ្ញាធរខេត្ត ស្រុក និង មន្ទីរកសិកម្ម និង រដ្ឋបាលជលផល)
- សកម្មភាពចូលរួមគាំទ្រ សហការ និង អនុវត្តគម្រោងរបស់សហគមន៍ឃុំជ្រោយប្រស់
- ការជួយសម្របសម្រួល និង គាំទ្របច្ចេកទេសចំពោះដំណើរការរៀបចំ និងការអនុវត្តន៏គម្រោងនេះ ដោយកម្មវិធីសិលា និង គ ជ វ វ នៃ គណៈកម្មាធិការប្រតិបត្តិខេត្តកោះកុង ។

## ៣.២. សកម្មភាពចាប់ផ្តើមដំណើរការគម្រោង:

ឆ្លើយតបទៅនឹងបញ្ហាប្រឈមដូចបានរៀបរាប់ខាងលើ កិច្ចប្រជុំពិគ្រោះយោបល់ជាបន្តបន្ទាប់ត្រូវបានរៀបចំឡើងរវាងអ្នកពាក់ព័ន្ធនានា ។ ពិសេសក្នុងឆ្នាំ២០០៥ ការប្រជុំពិគ្រោះយោបល់ចំនួន២លើកនៅថ្នាក់មូលដ្ឋាន បានប្រព្រឹត្តទៅនៅឃុំជ្រោយប្រស់ និង ឃុំកោះកាពិ ដោយមានការចូលរួមពីប្រជានេសាទ សមាជិកសហគមន៍ ក្រុមប្រឹក្សាឃុំ មន្ត្រីជំនាញជលផល និង ប៉ូលីសប៉ុស្តិ៍រដ្ឋបាលឃុំ ដោយមានការជួយសម្របសម្រួលពីមន្ត្រីកម្មវិធីសិលាខេត្ត និង ទីប្រឹក្សាកម្មវិធី ជាពិសេសដោយមានការជួយគាំទ្រផ្នែកគោលនយោបាយ និង ផ្លូវច្បាប់ពី ឯកឧត្តម **យុទ្ធ ភូថង** អភិបាលខេត្តកោះកុង និង ជាប្រធានគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត សហការណ៍ជាមួយរដ្ឋបាលជលផល ។ ជាលទ្ធផលនៃការប្រជុំនេះ ក៏បានឈានទៅដល់ការសម្រេចចិត្តរួមគ្នារវាងអ្នកពាក់ព័ន្ធ ចំពោះការផ្តួចផ្តើម រៀបចំសិក្សាស្រាវជ្រាវ អនុវត្តគម្រោងការបោះបង្គោល និង ប្រអប់ជម្រកមច្ឆាជាតិសិប្បនិម្មិត ដើម្បីការពារស្មៅសមុទ្រ ធនធានជលផល និងជីវចម្រុះផ្សេងៗ ក្នុងតំបន់ដែននេសាទសហគមន៍ឆ្នេរសមុទ្រឈ្លូងជ្រោយប្រស់ ក្នុងគោលបំណងលុបបំបាត់នូវរាល់បញ្ហាទំនាស់ទាំងឡាយដូចបានរៀបរាប់ខាងលើ ។ ដោយមានការជួយគាំទ្រទាំង ផ្នែកថវិកា និង បច្ចេកទេសពីកម្មវិធីសិលា និង គ ជ វ វ ខេត្តកោះកុង ។



កិច្ចប្រជុំពិគ្រោះយោបល់ជាមួយសហគមន៍នេសាទជ្រោយប្រស់ ពីវិធានការគ្រប់គ្រងធនធានជលផល

ពិនិត្យជារួមកិច្ចប្រជុំនេះបានបង្ហាញឱ្យឃើញថា ប្រជាពលរដ្ឋនៅមូលដ្ឋានភាគច្រើនមានការគាំទ្រចំពោះការងារអនុវត្តគម្រោងនេះ ដោយពួកគាត់មានបំណងប្រាថ្នាតែម្យ៉ាង គឺត្រូវធ្វើយ៉ាងណាឱ្យធនធានជលផលកើនឡើងវិញ ដើម្បីគាំទ្រជីវភាពរស់នៅរបស់ពួកគាត់ ។ តែការយល់ដឹងរបស់ពួកគាត់នៅពេលនោះ ពុំទាន់បានស៊ីជម្រៅលើការងារអនុវត្តន៏គម្រោងនៅឡើយ ។ ហេតុដូចនេះ បាននាំឱ្យអ្នកខ្លះហាក់បីដូចជាមានភាពស្ទាក់ស្ទើរ និង ភាពមិនទាន់ប្រាកដប្រជា ឬជំនឿជឿជាក់ថាតើការអនុវត្តន៏គម្រោងនេះអាចទទួលបានជោគជ័យ ឬយ៉ាងណា ? ដែលម្នាក់ៗទន្ទឹងរង់ចាំមើលអំពីលទ្ធផល និង ប្រសិទ្ធិភាពនៃការអនុវត្តន៏គម្រោងនេះ ។

**<u>សម្តីសមាជិកសហគមន៍នេសាទឃុំជ្រោយប្រស់:</u>** ការបោះបង្គោល និងប្រអប់ជម្រកត្រីនេះ វាជារឿងថ្មី សហគមន៍ពុំមានបទពិសោធន៏ឡើយ ។ យើងគ្រាន់តែបានដឹង និងឮថានៅប្រទេសថៃគេធ្លាប់អនុវត្តរបៀបប្រហាក់ប្រហែលគ្នានេះដែរ ក្នុងការគ្រប់គ្រងធនធានជលផលរបស់គេ ។ តែទោះបីជាយ៉ាងណាក៏ដោយយើងសង្ឃឹមថាការអនុវត្តន៏គម្រោងនេះប្រាកដជាអាចជួយដល់ការគ្រប់គ្រងធនធានជលផល និងអាចដោះស្រាយបញ្ហាទំនាស់នេសាទបានក្នុងកម្រិតណាមួយជាពុំខានឡើយ ។

**<u>សម្តីក្រុមមិនគាំទ្រការអនុវត្តគម្រោង</u>** (ភាគច្រើនអ្នកនេសាទអួនអូស ទូកឌុន និងមងខ្សែ): ការអនុវត្តន៏ គម្រោងនេះនឹងមិនអាចដោះស្រាយបញ្ហានេសាទក្នុងតំបន់នេះបានឡើយ ។ វាដូចជាខ្ជះខ្ជាយថវិកាក្នុងការដាក់ប្រអប់ និងបង្គោលទៅក្នុងសមុទ្រ ហើយរំខានដល់ការធ្វើនេសាទទៀតផង ។ តែយើងជឿថាការអនុវត្តគម្រោងនេះអាចធ្វើឱ្យធនធានជលផលកើនឡើង ហើយអ្នកនេសាទតូចតាចងាយស្រួលធ្វើនេសាទក្នុងតំបន់នេះ ជាងពេលមុនអនុវត្តគម្រោងពុំខាន ។

## ៤. លទ្ធផលសំរេចបាន:

ចាប់តាំងពីឆ្នាំ ២០០៥ រហូតដល់ ឆ្នាំ ២០០៨ នេះ ការអនុវត្តនីគម្រោងបោះបង្គោល និង ប្រអប់ជម្រកត្រីសិប្បនិម្មិត ក្នុងតំបន់ឈូងសមុទ្រជ្រោយប្រស់ សម្រេចបានលទ្ធផលដូចខាងក្រោម:

- បង្គោលសរុបចំនួន ២.២៨៨ ដើម
- ប្រអប់ជម្រកត្រីសរុបចំនួន ៥៥១ ប្រអប់ ។

បច្ចុប្បន្នគម្រោងនេះកំពុងតែបន្តការអនុវត្តនីសកម្មភាពការងារជាបន្តបន្ទាប់ ដែលពុំទាន់ចប់សព្វគ្រប់នៅឡើយ ។







### ៤.១- ឥទ្ធិពលរបស់គំរោង:

#### ៤.១.១- ផលអវិជ្ជមានដែលកើតឡើង:

- **បញ្ហាធ្វើចរាចរទូក:** នៅឆ្នាំដំបូងនៃការបោះបង្គោល និងប្រអប់ជម្រកត្រីសិប្បនិម្មិតនេះ បានបង្កឱ្យមានការលំបាកចំពោះការធ្វើចរាចរទូកឆ្លងកាត់តំបន់នេះ ជូនកាល

បានបង្កឱ្យមានភាពគ្រោះថ្នាក់ជាយថាហេតុ ដោយសារទូកបានបុកប៉ះទង្គិចបង្គោល ឬ ប្រអប់បេតុង ដែលនាំឱ្យកើតមានបញ្ហាទំនាស់រវាងអ្នកធ្វើចរាចរទូក ជាមួយការអនុវត្តន៏គម្រោង ។ មូលហេតុដោយសារតែ នៅពេលចាប់ផ្ដើមអនុវត្តគម្រោងពុំបានបោះបង្គោលកំណត់សំគាល់ព្រំប្រទល់តំបន់នេះឱ្យបានច្បាស់លាស់ជាមុនសិន ។

<u>សម្ដីអ្នកនេសាទជ្រោយប្រស់:</u> ដំបូងពួកយើងមានការពិបាកច្រើន និង បានខឹងសម្បាជាមួយការអនុវត្តន៏គម្រោងនេះ ដោយសារពុំមានការបោះបង្គោលព្រំកំណត់ទីតាំងបោះប្រអប់ និង បង្គោលជាមុន។ ដូច្នេះការបើកបរទូកកាណូត នៅពេលខ្លះមានការបុក ប៉ះទង្គិចនាំឱ្យខូចខាត និង គ្រោះថ្នាក់ជាយថាហេតុម្ដងម្កាលផងដែរ។

- **<u>បញ្ហាទីកន្លែងធ្វើនេសាទរួមតូចជាងមុនៈ</u>**

ការអនុវត្តន៏គម្រោងនេះបានបង្កភាពលំបាកចំពោះការធ្វើនេសាទ ដោយប្រភេទមងបណ្ដែត ដូចជាៈ មងបង្គា និង មងត្រីកាម៉ុង នៅក្នុងតំបន់ដែលបានបោះបង្គោល និង ប្រអប់ជម្រកត្រីសិប្បនិម្មិត ។ ជាទូទៅប្រភេទមងបណ្ដែតពុំអាចនេសាទក្នុងតំបន់នេះបានឡើយ ដោយសារសាច់មង អាចទាក់រហែកជាមួយនឹងបង្គោល ឬ ប្រអប់ ។

សម្ដីរបស់ **លោក យ៉ាន រដ្ឋ** អ្នកនេសាទឃុំជ្រោយប្រស់: ខ្ញុំយល់ថាការបោះបង្គោល និងប្រអប់ជម្រកត្រី ធ្វើឱ្យដែននេសាទសម្រាប់ការធ្វើនេសាទត្រីកាម៉ុងរបស់ខ្ញុំត្រូវរួមតូច ដែលពីមុនដែននេសាទធំទូលាយជាង និង ងាយស្រួលចាប់ត្រីកាម៉ុងបានច្រើនជាង ។ ប៉ុន្តែខ្ញុំនិយាយដូច្នេះមិនមែនមានន័យថា ផលត្រីកាម៉ុងក្នុងធម្មជាតិថយចុះបន្ទាប់ពីការអនុវត្តន៏គម្រោងនេះទេ តែប្រហែលជាហ្វូងត្រីកាម៉ុងវាអាចមានឱកាសងាយស្រួល រត់គេចវេសទៅជ្រកកោននៅកន្លែងបោះបង្គោល និងប្រអប់ ជាហេតុនាំឱ្យយើងចាប់វាមិនបានច្រើនដូចមុន។

- **បញ្ហាបទល្មើសនេសាទដោយប្រើរូបភាពថ្មី:** ក្នុងតំបន់ដែនការពារ ដែលបានបោះបង្គោល និងប្រអប់ជម្រកត្រីនេះ ត្រូវបានជនខិលខូចលួចប្រព្រឹត្តបទល្មើសនេសាទតាមរូបភាពថ្មីដោយប្រើមងអួនហ៊ុំព័ទ្ធចាប់ត្រីដែលបានមករស់កុំនៅក្នុងទីកន្លែងដែលបានបោះជម្រកត្រីសិប្បនិម្មិត និងប្រើវិធីនេសាទដោយទូកខុនជាមួយនឹងការបោះតម្រុយសំគាល់ទីតាំងដែលបានបោះប្រអប់ជម្រកត្រីដើម្បីជៀសវាងការបុក ឬ ប៉ះទង្គិច ។ម្តងម្កាលក៏មានអ្នកមកពីខាងក្រៅលួចធ្វើនេសាទដោយប្រើថ្នាំបំពុលក្នុងតំបន់ដាក់ប្រអប់ជម្រកត្រីផងដែរ ។

> សម្តី**អ្នកស្រី អ៊ុន យ៉ាន** អនុប្រធានគណៈកម្មការសហគមន៍នេសាទជ្រោយប្រស់: ខ្ញុំទទួលស្គាល់ថាបទល្មើសនេសាទនៅតែមាន ប៉ុន្តែថយចុះយ៉ាងច្រើន បើធៀបទៅនឹងមុនពេលអនុវត្តគម្រោង។ ខ្ញុំយល់ថាការដាក់ប្រអប់ជម្រកត្រីនេះ មានគំលាតឆ្ងាយពីគ្នាពេក ជាហេតុនាំឱ្យបទល្មើស នេសាទដោយទូកខុនតូចៗ នៅតែមានឱកាសក្នុង ការលួចចូលធ្វើនេសាទក្នុងតំបន់នេះនៅឡើយ ។ សំណូមពររបស់ខ្ញុំ គួរតែពិចារណាការដាក់ប្រអប់ជម្រកត្រី ឱ្យបានញឹកជាងមុន ដើម្បីបញ្ឈប់បទល្មើសនេសាទដោយទូកខុន។ កន្លងមកក៏មានលេចឮពាក្យចចាមអារាមថា ប្រអប់ជម្រកត្រីនេះត្រូវបានពួកអ្នកនេសាទទូកខុននាំគ្នាទាញអូសចេញទៅគរផ្តុំគ្នាមួយកន្លែង ដើម្បីយកកន្លែងធ្វើនេសាទ ។ ប៉ុន្តែខ្ញុំយល់ថាករណីនេះ ប្រហែលមិនអាចធ្វើទៅរួចទេ ព្រោះប្រអប់ជម្រកត្រីនីមួយៗមានទម្ងន់ធ្ងន់ណាស់។ ម្យ៉ាងទៀតវានៅក្នុងទឹកជ្រៅពិបាកមើលឃើញ និង ចាត់ការទៀតផង ។ ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំនឹងតាមដានរឿងនេះឱ្យបានដឹងការពិត ។

- **ការកើនឡើងចំនួនប្រជានេសាទពីតំបន់ខាងក្រៅ:** មកនេសាទក្នុងតំបន់ឈូងសមុទ្រជ្រោយប្រស់ ដោយធនធាននេសាទក្នុងតំបន់នេះត្រូវបានកើនឡើងវិញ ពិសេសប្រភេទឧបករណ៍ លបក្តាម និង មងក្តាម ។ ការកើនឡើងចំនួនអ្នកនេសាទក្នុងតំបន់

ដែននេសាទសហគមន៍ជ្រោយប្រស់ គឺអាចបណ្តាលឱ្យកើតមានបញ្ហាប្រឈមជាថ្មី សម្រាប់ការគ្រប់គ្រងធនធាននេសាទក្នុងតំបន់នេះ ។ ប្រហែលជាកំណើនផលស្តុកនៃមច្ឆាជាតិក្នុងធម្មជាតិតាមរយៈនៃការអនុវត្តន៍គម្រោងនេះ នឹងពុំអាចធានាបាននូវលំនឹង ឬ ចីរភាពបានឡើយ ជាមួយនឹងកំណើននៃការធ្វើនេសាទដែលកំពុងតែកើនឡើងនេះ ប្រសិនបើពុំមានវិធានការគ្រប់គ្រងជាក់លាក់ណាមួយបន្ថែមទៀត ចំពោះការកើនឡើងនៃចំនួនអ្នកនេសាទនេះ ។

**លោក ប្រាក់ សូវ៉ាត និង លោក លី ឈាន** គណៈកម្មការសហគមន៍នេសាទជ្រោយប្រស់: ដោយសារផលនេសាទចាប់ផ្តើមសម្បូរឡើងវិញ អ្នកនេសាទមកពីខាងក្រៅក៏កើនឡើងជាបន្តបន្ទាប់ដែរ ។ ដូច្នេះអ្នកនេសាទក្នុងភូមិជ្រោយប្រស់របស់យើង នៅតែជួបការលំបាក ពីព្រោះការនេសាទរបស់អ្នកភូមិយើងមិនទាន់( មិនឈ្នះ) អ្នកនេសាទដែលមកពីខាងក្រៅ ។ ពួកគេពុំបានចូលរួមការពារធនធាននេសាទក្នុងតំបន់នេះទេ តែពួកគេមានលទ្ធភាពចាប់បានផលនេសាទច្រើនជាងពួកយើងទៅវិញ ។ម្តងម្កាលពួកគេបានបង្កការលួចឧបករណ៍នេសាទរបស់អ្នកភូមិជ្រោយប្រស់យើងទៀតផង ។

## ៤.១.២- <u>ផលវិជ្ជមានដែលកើតឡើង:</u>

ដោយសារតំបន់នេះត្រូវបានការពារ និង អភិរក្សឡើងវិញតាមរយៈការអនុវត្តន៍គម្រោងដាក់ប្រអប់ និង បោះបង្គោល បទល្មើសនេសាទត្រូវបានថយចុះ អេកូឡូស៊ីដែននេសាទក៏ត្រូវបានកែលម្អ រីឯពពួកមច្ឆាជាតិក៏ចាប់ផ្តើមចូលមករស់នៅក្នុងតំបន់នេះឡើងវិញ ។ ជាទូទៅបន្ទាប់ពីការអនុវត្តន៍គម្រោងបានរយៈពេល១ឆ្នាំកន្លងមក (ឆ្នាំ ២០០៧) ប្រជានេសាទឃុំជ្រោយប្រស់បានកត់សម្គាល់ និង ភ្ញាក់ផ្អើលចំពោះការប្រែប្រួលនូវផលនេសាទក្តាមថ្ម និង ក្តាមសេះដែលពួកគាត់នេសាទបាន គឺមានចំនួនកើនឡើងលើសពី

**លោក គ្រួច ផេង** ជំទប់ទី១ ឃុំជ្រោយប្រស់បានអះអាងថា ធនធានផលនេសាទសមុទ្រកំពុងកើនឡើងបន្ទាប់ពីការអនុវត្តន៍គម្រោង ពិសេសក្តាមសេះ និង ក្តាមថ្ម អ្នកនេសាទឃុំជ្រោយប្រស់អាចចាប់បានច្រើនជាងមុនគួរឱ្យកត់សំគាល់ ។

ការស្នាទរបស់ពួកគាត់ ។ តាមការសង្កេតជាក់ស្តែងនៅក្នុងតំបន់ដែលបានដាក់ប្រអប់ជម្រកត្រីនេះ គឺមានហ្វូងត្រីតូចៗ ជាច្រើនបានមកកុំគ្នារស់នៅក្នុងតំបន់នេះ ។ ដោយសាទីនេះមានជម្រកសុវត្ថិភាព សម្រាប់ពពួកមច្ឆាជាតិ ដែលអាចគេចផុតពីការរំខានផ្សេងៗតាមរយៈការធ្វើនេសាទ ។ ការកើនឡើងនូវផលនេសាទក្តាមថ្ម និង ក្តាមសេះ គឺអាចបណ្តាលមកពីស្មៅសមុទ្រ និង អេកូឡូស៊ីដែននេសាទត្រូវបានកែលម្អឡើងវិញជាមួយនឹងការកើនឡើងវិញ នូវ ពពួកជីវៈចម្រុះនានាក្នុងតំបន់នេះ ។ ម្យ៉ាងទៀតកូនក្តាមតូចៗក្នុងតំបន់នេះ ត្រូវបានការពារឱ្យរួចផុតពីការបំផ្លិចបំផ្លាញនៃការនេសាទដោយទូកឌុន និង អួនអូស ដែលជាប្រភេទឧបករណ៍នេសាទចាប់មិនរើសមុខ ដោយចាប់យកទាំងធំទាំងតូច ចម្រុះប្រភេទផលនេសាទ ។ ទោះបីជាយ៉ាងក៏ដោយ ការសិក្សាលម្អិត តាមលក្ខណៈបច្ចេកទេស សម្រាប់ជាមូលដ្ឋានក្នុងការបកស្រាយ និងការសន្និដ្ឋាន ចំពោះអំណះអំណាង ខាងលើ គឺពុំទាន់បានអនុវត្តនៅឡើយ ។

*ការប្រៀបធៀបកត្តាប្រែប្រួលសំខាន់ៗនៅពេលមុន និងក្រោយអនុវត្តគម្រោងនៅឈូងជ្រោយប្រស់*

| *បរិយាយ* | *មុនពេលអនុវត្តគម្រោង* | *ក្រោយពេលអនុវត្តគម្រោង* |
|---|---|---|
| *បទល្មើសនេសាទដែលកើតមាន* | *១០០ ភាគរយ* | *២០-៤០ ភាគរយ* |
| *បរិមាណផលនេសាទក្តាម/ម្នាក់/ថ្ងៃ* | *៦-៧ គ.ក្រ* | *១២-៣៥ គ.ក្រ* |
| *ប្រាក់ចំណូលពីនេសាទក្តាម/ម្នាក់/ថ្ងៃ* | *១០០.០០០ រៀល* | *៣០០.០០០- ៤០០.០០០រៀល* |

## ប្រព័ន្ធអេកូឡូស៊ីតំបន់ស្មៅសមុទ្រត្រូវបានកែលម្អ:

តំបន់ស្មៅសមុទ្រត្រូវបានការពារឱ្យបានរួចផុតពីការលុកលុយធ្វើនេសាទផ្សេងៗ ពិសេសទូកឌុន ហើយលក្ខខណ្ឌនៃការដុះលូតលាស់របស់ស្មៅសមុទ្រមានភាពល្អប្រសើរជាងមុន។ ស្មៅសមុទ្រ

សម្តីអ្នកស្រី **អ៊ិន យ៉ាន** និង **លោក យ៉ៃ សុខយាន** សមាជិកសហគមន៍នេសាទជ្រោយប្រស់:ឥឡូវនេះស្មៅ សមុទ្រកំពុងដុះលូតលាស់ល្អជាងមុនឆ្ងាយណាស់ ហើយ កន្លែងខ្លះបានដុះរីករាលដាលទៅកាន់កន្លែងថ្មីថែមទៀត និងពុំមានទូកឌុនណាមកបំផ្លាញស្មៅសមុទ្រដូចពីមុនឡើយ។ រីឯកករល្អក់នៅក្នុងតំបន់ស្មៅសមុទ្រក៏ពុំកើតមានឡើងដូចពីមុនដែរ។ សព្វថ្ងៃកូនត្រីតុកកែក្នុងតំបន់ ស្មៅសមុទ្រកំពុងតែសម្បូរឡើងវិញទៀតផង

មានតួនាទីយ៉ាងសំខាន់លើវិស័យជលផល ជាជម្រករស់នៅរបស់ពពួកមច្ឆជាតិនិង ជីវៈចម្រុះនានាជាប្រភពផលិត និង ផ្តល់ចំណីអាហារធម្មជាតិដ៏សំខាន់ដល់មច្ឆាជាតិ ព្រមទាំងជួយរក្សាការពារលំនឹងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ឆ្នេរថែមទៀតផង ។

- **ការកើនឡើងវិញនូវធនធានជលផលៈ**

ក្រៅពីផលនេសាទក្តាមថ្ម និង ក្តាមសេះដែលកំពុងកើនឡើង ប្រភេទធនធាននេសាទផ្សេងទៀត ក៏មានការកើនឡើងផងដែរ ដូចជាៈប្រភេទបង្គា មឹគ ខ្យង គ្រុំ និងត្រីផ្សេងៗ ពិសេសពពួកត្រីតុកកែ និង ពពួកត្រីឆ្លង់ ។

សម្តីអ្នកនេសាទជ្រោយប្រស់ និង **លោក ប្រាក់ សូវ៉ាត** ប្រធានសហគមន៍នេសាទជ្រោយប្រស់ៈ ដោយសារគុណសម្បត្តិនៃការអនុវត្តគម្រោងនេះ ប្រអប់ជម្រកត្រីភាគច្រើនមានត្រីតូចធំមកជ្រកនៅដូចជាៈ ពពួកត្រីឆ្លង់ ត្រីតុកកែ ត្រីកាតាំង និងប្រភេទត្រីផ្សេងៗទៀត ។ ជារឿយៗអ្នកស្ទូចត្រីតែងតែស្ទូចត្រីបានយ៉ាងងាយស្រួលក្នុងតំបន់ ដាក់ប្រអប់ជម្រកត្រីនេះ។ ពិសេសទៅទៀតមានគ្រុំចំពុះទាជាច្រើនបានមកតោងរស់ នៅលើបង្គោល និងប្រអប់ជម្រកត្រីនេះ កន្លងមកអ្នកនេសាទមកពីឡាំដាំបានមកប្រមូលផលគ្រុំចំពុះទានេះបានយ៉ាងច្រើនទៀតផង ។

សំរាប់អ្នកនេសាទប្រើឧបករណ៍តូចតាច និង លក្ខណៈគ្រួសារ ពួកគាត់ងាយស្រួលក្នុងការធ្វើនេសាទជាងមុន ។ ពួកគាត់អាចធ្វើនេសាទបាននៅក្បែរផ្ទះដោយមិនចាំបាច់ធ្វើដំណើរទៅនេសាទឆ្ងាយពីផ្ទះ ហើយក៏មិនភ័យព្រួយចំពោះការខូចខាត និងបាត់បង់ឧបករណ៍នេសាទដែលបង្កឡើងដោយទូកខុន និងទូកអួនអូសទៀតឡើយ ។

**លោក លី ឈាង** សមាជិកសហគមន៍បានអះអាងថាៈ ឆ្នាំនេះយើងសំគាល់ឃើញថា រយៈពេលអាចនេសាទក្តាមសេះ មានរយៈពេលវែងជាងបណ្តាឆ្នាំកន្លង ទោះបីជាក្នុងរដូវវស្សាក៏អាចនេសាទបានជាបន្តបន្ទាប់ ។ នេះអាចបណ្តាលមកពីការអនុវត្តគម្រោងបោះបង្គោល និងប្រអប់ជម្រកត្រី រួមផ្សំជាមួយនឹងកត្តាអាកាសធាតុអំណោយផលចំពោះការនេសាទផងដែរ

សម្តី**លោក យ៉ាន រដ្ឋ** អ្នកនេសាទជ្រោយប្រស់អះអាងថា: បើកុំតែបានដាក់ប្រអប់ជម្រកត្រី និងបោះបង្គោលទាន់ នោះធនធានជលផលក្នុងឈូងជ្រោយប្រស់ប្រហែលជាខ្ទេចខ្ទីម៉ត់ឈឹងអស់ទៅហើយ ។ ម្ល៉ោះប្រហែលនៅពេលនេះមិនមានផលនេសាទគ្រប់គ្រាន់ក្នុងការនេសាទឡើយ ។ ជាទូទៅ ការកើនឡើងនូវផលនេសាទ យើងនៅពិបាកមើលឃើញណាស់ ពីព្រោះឥឡូវកំណើនអ្នកនេសាទច្រើន។ ប៉ុន្តែអ្វីដែលខ្ញុំអាចមើលឃើញគឺ រហូតដល់ពេលនេះយើងអាចរក្សាបាននូវលំនឹងផលចាប់ និង ប្រភេទមួយចំនួនមានការកើនឡើងជាងមុន ដូចជាក្តាមសេះ និង ក្តាមថ្ម។ ម្យ៉ាងទៀត ក្នុងឆ្នាំ២០០៨ នេះ ខ្ញុំសំគាល់ឃើញថាការនេសាទក្តាមសេះអាចនេសាទបានជាប់លាប់ និង អាចនេសាទបានក្នុងរយះពេលវែងជាងបណ្តាឆ្នាំមុនៗ ដែលការនេសាទក្តាមសេះបានមានរយះពេលខ្លី និងពុំអាចធ្វើនេសាទជាប់លាប់បានឡើយ ។

- **បទល្មើសនេសាទ និង ជម្លោះនេសាទត្រូវបានកាត់បន្ថយ:**

ដោយសារការបោះប្រអប់ និង បង្គោលការពារ ជម្រកត្រីនេះ នាំឱ្យបញ្ហាទំនាស់ និង

**អ្នកស្រី ត្រេស យ៉ានី** និង **អ្នកស្រី អ៊ុន យ៉ាន** ក្រុមប្រឹក្សាឃុំ និងសមាជិកសហគមន៍នេសាទជ្រោយប្រស់បានអះអាងថា: ជាការប្រសើរបំផុត ចំពោះការអនុវត្តន៍គម្រោងនេះវាបានជួយសហគមន៍ និង ក្រុមសមត្ថកិច្ចយើងមិនចាំបាច់ចេញទៅល្បាតញឹកញាប់ដូចមុនទៀតឡើយ។ ដូច្នេះយើងអាចកាត់បន្ថយការចំណាយបានយ៉ាងច្រើន ចំពោះការងារល្បាត និងមានពេលវេលា ដើម្បីប្រកបរបរផ្សេងៗទៀត។ ពិសេស សហគមន៍យើងលែងមានបញ្ហាប្រឈមជាមួយអ្នកនេសាទល្មើសច្បាប់ទៀតហើយ ។

ជម្លោះនេសាទក្នុងដែនសហគមន៍ត្រូវបានកាត់បន្ថយ ដូចជា: បទល្មើសនេសាទដោយទូកឌុន និង អួនអូសស្ទើរតែត្រូវបានលុបបំបាត់ទាំងស្រុង ។ ពិសេសអំពើហឹង្សាវាយតបគ្នាដែលធ្លាប់បានកើតឡើង ក្នុងដែននេសាទសហគមន៍ រវាងក្រុមល្បាតនៃសហគមន៍ជ្រោយប្រស់ ជាមួយ នឹងអ្នកនេសាទទូកឌុន

និង អួនអួសដែលមកពីខាងក្រៅ ក៏ពុំមានកើតឡើងទៀតឡើយ ។ ការខូចខាត និង ការបាត់បង់ឧបករណ៍នេសាទ ដូចជា: ពពួកមង និង លប ដោយសារសកម្មភាពរបស់ ទូកឌុន និងអួនអួសក៏បានដោះស្រាយ ។ បញ្ហាទំនាស់រវាងអ្នកនេសាទ និង សមត្ថកិច្ច ពាក់ព័ន្ធនានា ចំពោះការគ្រប់គ្រងក្នុងតំបន់ដែននេសាទជ្រោយប្រស់ក៏ត្រូវបានធូរ ស្បើយ ។ សរុបសេចក្តីមក បន្ទាប់ពីការអនុវត្តគម្រោងនេះមក ទាំងសហគមន៍នេសាទ ក៏ដូចជាស្ថាប័នមានសមត្ថកិច្ចនានា កាន់តែមានភាពងាយស្រួល ចំពោះការងារគ្រប់ គ្រងធនធានជលផលនៅក្នុងតំបន់នេះ ។

- **ការផ្លាស់ប្តូរប្រភេទឧបករណ៍នេសាទ:** អ្នកនេសាទមួយចំនួនតូច ដែលធ្លាប់បាន ប្រើប្រាស់ឧបករណ៍នេសាទដែលហាមឃាត់ និង ខុសច្បាស់ក្នុងដែននេសាទសហគមន៍ ដូចជា: មងខ្វូវ ឈិបយន្ត និង អួនអួសទឹករាក់ មានការផ្លាស់ប្តូរគំនិត ដោយបាន និង កំពុងព្យាយាមប្តូរមកប្រើឧបករណ៍នេសាទស្របច្បាប់វិញជាបន្តបន្ទាប់ ។

**លោក ឃៃ សុខយាន** សមាជិកសហគមន៍នេសាទជ្រោយប្រស់: បានអះអាងថា: ឥឡូវនេះអ្នកនេសាទមងខ្វូវមួយចំនួនក្នុងឃុំជ្រោយប្រស់ ក៏បានផ្លាស់ប្តូរមកប្រើ ឧបករណ៍នេសាទស្របច្បាប់វិញប្រមាណជា ៥០ ភាគរយ ។

- **ភាពអំណោយផលដល់អ្នកនេសាទក្រីក្រ:**

ដោយសារធនធាននេសាទក្នុងដែនសហគមន៍ត្រូវបានកើនឡើង វាបានផ្តល់ឱកាស សម្រាប់អ្នកនេសាទក្រីក្រ ប្រើប្រាស់ឧបករណ៍នេសាទតូចតាច ពិសេសស្ត្រី និង កុមារ ដែលសុទ្ធសឹងតែពុំមានលទ្ធភាពចេញទៅធ្វើនេសាទនៅសមុទ្រក្រៅឆ្ងាយពីផ្ទះ ។ ឥឡូវពួកគេអាចមានភាពងាយស្រួល ចំពោះការធ្វើនេសាទនៅតាមឆ្នេរជិតៗផ្ទះ ពុំចាំ បាច់ចំណាយថវិកា និង ពេលវេលាច្រើន ដោយទទួលបានផលនេសាទល្មមគ្រប់គ្រាន់ ព្រមទាំងធានាបាននូវសុវត្ថិភាពក្នុងការធ្វើនេសាទរបស់ពួកគេទៀតផង ។

សម្តី **លោក យ៉ាន រដ្ឋ:** ឥឡូវនេះយើងអាចនេសាទបាននៅជិតៗភូមិ បើនេសាទនៅពេលយប់វិញ អ្នកនេសាទមិនចាំបាច់ព្រួយបារម្ភដេកយាមលប និង មង របស់គេ ដើម្បីការពារឱ្យគេចផុតពីការបំផ្លិចបំផ្លាញ ដោយទូកឌុន ឬ អួនអូស ដូចពេលមុនៗទៀតឡើយ ។ ពួកគេអាចវិលមកដេកនៅផ្ទះវិញ លុះពេលព្រឹកឡើង ទើបទៅលើកលប ឬ សារមងរបស់ពួកគេ ។

- **ការរៀនសូត្រ និង ផ្តល់បទពិសោធន៍ចំពោះការគ្រប់គ្រងធនធានជលផល:**

ប្រជានេសាទមួយចំនួនដែលធ្លាប់មានការថ្នាំងថ្នាក់ និង មិនពេញចិត្តចំពោះការអនុវត្តនីគម្រោងបោះបង្គោល និង ប្រអប់ជម្រកត្រីសិប្បនិម្មិតនេះ បច្ចុប្បន្នឆ្លងតាមបទពិសោធន៍នៃការអនុវត្តនីគម្រោង ពួកគេភាគច្រើនមានការផ្លាស់ប្តូរគំនិតមកគាំទ្រវិញ ព្រមទាំងមានការជឿជាក់ និងទទួលស្គាល់ថាការអនុវត្តនីគម្រោងនេះនាំឱ្យស្មៅសមុទ្រត្រូវបានការពារយ៉ាងពិតប្រាកដ និង ញុំាងឱ្យមានការកើនឡើងនូវផលនេសាទក្នុងតំបន់ជ្រោយប្រស់នេះ ។ ម្យ៉ាងវិញទៀត ស្ថាប័នជំនាញ អាជ្ញាធរ និង អ្នកពាក់ព័ន្ធផ្សេងៗកាន់តែមានការគាំទ្រយ៉ាងផុសផុល ដូចជា: រដ្ឋបាលជលផល, អាជ្ញាធរខេត្ត ស្រុក ឃុំ និង សហគមន៍នេសាទជ្រោយប្រស់ ព្រមទាំងគម្រោង និង អង្គការមិនមែនរដ្ឋាភិបាលផ្សេងៗជាច្រើនទៀត ។

បច្ចុប្បន្ន តំបន់នេះបានក្លាយជាទីកន្លែងសម្រាប់ការសិក្សាស្វែងយល់ ដកបទពិសោធន៍សម្រាប់ការអនុវត្តនីគម្រោងការពារ និងអភិរក្សធនធានជលផលទៀតផង ។ ជាបន្តបន្ទាប់ បទពិសោធន៍នេះត្រូវបានចែករំលែកទៅតំបន់ផ្សេងៗទៀត ក្នុងខេត្តកោះកុងមាន:ស្រុកស្រែអំបិល ស្រុកបូទុមសាគរ ស្រុកគិរីសាគរ និងស្រុកមណ្ឌលសីមា ក្នុងការអនុវត្តនីគម្រោងគ្រប់គ្រងធនធានជលផលរបស់ស្រុកនីមួយៗ ។ ជាពិសេស បណ្តាគម្រោង និង សហគមន៍នានា មកពីខេត្តផ្សេងៗក៏កំពុងចាប់អារម្មណ៍ និង បានមកធ្វើទស្សនកិច្ចជាហូរហែ ដើម្បីសិក្សាស្វែងយល់ រៀនសូត្រ ដកបទពិសោធន៍

ចំពោះការអនុវត្តន៏គម្រោង សម្រាប់ការគ្រប់គ្រងធនធានជលផលនៅតាមមូលដ្ឋានរបស់ពួកគេ ។

## ៤.២- ការប្រៀបធៀបភាពប្រែប្រួលក្នុងសហគមន៏នេសាទជ្រោយប្រស់មុន និង ក្រោយពេលអនុវត្តគម្រោង:

| ល.រ | បរិយាយ | មុនពេលអនុវត្តគម្រោង | ក្រោយពេលអនុវត្តគម្រោង |
|---|---|---|---|
| ១ | ពពួកជីវចំរុះ និង លក្ខខណ្ឌបរិស្ថានក្នុងដែននេសាទសហគមន៏ | ទីជម្រករបស់មច្ឆាជាតិត្រូវរងការខូចខាត ស្មៅសមុទ្ររងការបំផ្លិចបំផ្លាញ និង ធនធានជលផលថយចុះយ៉ាងខ្លាំង ដោយសារសកម្មភាពនេសាទ | ទីជម្រករបស់មច្ឆាជាតិ និង ស្មៅសមុទ្រត្រូវបានការពារ និងកែលម្អ ធនធានជលផលត្រូវបានការពារ និង ផ្សោតចាប់ផ្តើមសម្បូរឡើងវិញ |
| ២ | ទីកន្លែងធ្វើនេសាទ | ចេញទៅនេសាទឆ្ងាយពីភូមិពេលខ្លះត្រូវដេកយប់ ចំណាយលើប្រេងឥន្ទនៈច្រើន | អាចធ្វើនេសាទនៅជិតភូមិ ចំណាយ លើប្រេងឥន្ទនៈតិចជាងមុន |
| ៣ | ពេលវេលាចេញទៅនេសាទ ក្នុង ១ថ្ងៃ | ចំណាយពេលច្រើន ជាមធ្យម ពី៨ ទៅ ១០ ម៉ោង | ចំណាយពេលតិចជាងមុន ជាមធ្យមពី ៣ ទៅ ៥ ម៉ោង |
| ៤ | ប្រភេទផលនេសាទដែលអាចនេសាទបាន | បង្គា, ក្តាមសេះ, ក្តាមថ្ម, ត្រីកាម៉ុង ត្រីឆ្កង់ ត្រីតុកកែ,... ថយចុះ ( ប្រភេទមិនប្រែប្រួល តែបរិមាណផលថយចុះ) | បង្គា, ក្តាមសេះ, ក្តាមថ្ម, ត្រីកាម៉ុង ត្រីឆ្កង់ ត្រីតុកកែ,... កើនឡើង ( បរិមាណ ផលកើនឡើងជាងពេលមុន បន្តិច) |

| | | | |
|---|---|---|---|
| ៥ | ការប្រែប្រួលទំហំតាមប្រភេទ ផលនេសាទនីមួយៗ | ជារួមទំហំមធ្យាជាតិតូចៗ | ទំហំមធ្យាជាតិតូចៗភាគច្រើន និង ទំហំធំមានការកើនឡើងជាងមុន |
| ៦ | បរិមាណផលនេសាទបានក្នុង ១ថ្ងៃ ក្នុងអ្នកនេសាទម្នាក់ | ក្នុងរដូវនេសាទត្រូវៈ ក្តាមសេះ ៦-៧ គក្រ ត្រីកាម៉ុង២០០-៣០០គក្រ | ក្នុងរដូវនេសាទត្រូវៈ ក្តាមសេះ ១២-៣៥ គ ក្រ ត្រីកាម៉ុង ៣០០-៥០០ គក្រ |
| ៧ | ប្រាក់ចំណូលនេសាទក្នុង ១ ថ្ងៃ របស់អ្នកនេសាទម្នាក់ៗ គិតជាមធ្យម | នេសាទក្តាមថ្មពេលនេសាទត្រូវ ១០០.០០០រៀល | នេសាទក្តាមថ្ម ពេលនេសាទត្រូវៈ ៣០០.០០០- ៤០០.០០០រៀល |
| | | នេសាទទូទៅពេលនេសាទត្រូវ ៣៦.០០០-៤៥.០០០រៀល ពេលនេសាទមិនត្រូវៈ ១៤.៣០០-៤០.០០០រៀល | នេសាទទូទៅ ពេលនេសាទត្រូវៈ ១២០.០០០-២០០.០០០ រៀល ពេលនេសាទមិនត្រូវៈ ១០០.០០០-១៥០.០០០ រៀល |
| ៨ | ឱកាសក្នុងការប្រកបរបរផ្សេងៗ | ពុំមានពេលសម្រាប់ប្រកបរបរផ្សេងទៀតទេ | មានពេលទំនេរអាចប្រកបរបរផ្សេងទៀតបាន, មិនចាំបាច់ដេកយាម ឧបករណ៍នេសាទនៅពេលយប់ |
| ៩ | ការខូចខាត និង បាត់បង់ឧបករណ៍នេសាទ | ប្រឈមការខូចខាតបាត់បង់ឧបករណ៍នេសាទខ្ពស់ដោយទូកឌុន ទូកអួនអូស បំផ្លាញ និង ចោរលួច | ការខូចខាត ការបាត់បង់ឧបករណ៍នេសាទ ដោយសារទូកឌុន និង អួនអូសបានថយចុះប្រមាណ ៥០ភាគរយ ។ |

| | | | |
|---|---|---|---|
| ១០ | សកម្មភាពល្មើសនេសាទក្នុងដែនសហគមន៍ | មានបទល្មើសច្រើន ដូចជាៈ ទូកឌុន ទូកអួនអូស មងខ្វរ ទឹករាក់ ទំនាស់កើតឡើង ផតឈប់ឈរ ស្មុគស្មាញ ពិបាកដោះស្រាយ អំពើហឹង្សាកើតឡើងជារឿយៗ | បទល្មើសនេសាទ និង ជម្លោះនេសាទ ថយចុះប្រមាណជា ៦០-៨០ ភាគរយ ពិសេសទូកឌុន និងអួនអូស ។ ពុំមានអំពើហឹង្សាកើតឡើង និង ងាយស្រួលក្នុងការគ្រប់គ្រងជាងមុន |
| ១១ | សកម្មភាពល្បាតរបស់សហគមន៍នេសាទជ្រោយប្រស់ | សកម្មភាពល្បាតមមាញឹកខ្លាំង ថវិកាចំណាយលើការងារល្បាតច្រើន | សកម្មភាពល្បាតបានកាត់បន្ថយប្រមាណ ៥០ ភាគរយ |
| ១២ | សកម្មភាពនេសាទរបស់អ្នកនេសាទក្រីក្រ តូចតាច ស្ត្រី និង កុមារដែលពុំមានលទ្ធភាពចេញទៅធ្វើនេសាទឆ្ងាយពីភូមិ | ជួបការលំបាកយ៉ាងខ្លាំង ដោយការធ្វើនេសាទក្បែរភូមិពុំអាច ចាប់បានផលនេសាទគ្រប់គ្រាន់ | បង្កភាពងាយស្រួលជាងមុន ដោយអាចធ្វើនេសាទបាននៅក្បែរៗភូមិ |
| ១៣ | បំរែបំរួលចំពោះការប្រើប្រាស់ឧបករណ៍នេសាទ | មានប្រើប្រាស់ប្រភេទឧបករណ៍ល្មើសច្បាប់ច្រើន | ឧបករណ៍ល្មើសច្បាប់ ថយចុះ មានការប្តូរមកប្រើឧបករណ៍ស្របច្បាប់ជាបន្តបន្ទាប់ ។ |

*(**ប្រភពៈ** អ្នកនេសាទ និង សហគមន៍នេសាទឃុំជ្រោយប្រស់ ឆ្នាំ ២០០៨)*

## ៥. ការសន្និដ្ឋាន:

- ជារួមការអនុវត្តន៏គម្រោងនេះពិតជាទទួលបាននូវភាពជោគជ័យ ដោយទទួលបានការគាំទ្រយ៉ាងខ្លាំងក្លាពី ឯកឧត្តមអភិបាលខេត្តកោះកុង អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និង ស្ថាប័នជំនាញជលផល ចំពោះការអនុវត្តន៏គម្រោង ការចូលរួមពីគម្រោង និង អង្គការអភិវឌ្ឍន៏នានា ពិសេសការចូលរួមអនុវត្តរបស់សហគមន៏ និង ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដោយឆ្លើយតបនឹងគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការទៀតផង ។
- បរិស្ថានដែននេសាទក្នុងតំបន់ឈូងសមុទ្រជ្រោយប្រស់ ជាបណ្តើរ១ត្រូវបានកែលម្អ ធនធានស្មៅសមុទ្រ និង ជលផលកំពុងមានភាពល្អប្រសើរឡើងវិញ ព្រមទាំងអាចជួយសម្រួលដល់អ្នកនេសាទតូចតាច បង្កលក្ខណៈកាន់តែងាយស្រួលក្នុងការប្រកបរបរចិញ្ចឹមជីវិត តាមរយៈការធ្វើនេសាទក្នុងតំបន់ឈូងសមុទ្រជ្រោយប្រស់ ពិសេសការធ្វើនេសាទក្តាមសេះ ក្តាមថ្ម និង ការប្រមូលផលគ្រុំ ចំពុះទា ដែលតោងរស់នៅតាមបង្គោល និង ប្រអប់ជម្រកត្រីសិប្បនិម្មិត ។
- ថ្វីត្បិតតែធនធានស្មៅសមុទ្រ និង ធនធានជលផលកំពុងត្រូវបានការពារ និង កើនឡើងជាបន្តបន្ទាប់ ប៉ុន្តែការកើនឡើងនូវអ្នកនេសាទមកពីខាងក្រៅមានចំនួនច្រើន ជាមួយនឹងភាពពុំមានសមធមិនៃ ការទាញយកផលនេសាទក្នុងតំបន់នេះ រវាងអ្នកនេសាទខាងក្នុង និង អ្នកខាងក្រៅ ។ ដោយអ្នកមកពីខាងក្រៅមានលទ្ធភាពចាប់ផលនេសាទបានច្រើនជាងអ្នកខាងក្នុង ជាហេតុនាំឱ្យអ្នកខាងក្នុងសហគមន៏ជ្រោយប្រស់ដែលជាអ្នកចូលរួមក្នុងការគ្រប់គ្រងការពារធនធានជលផល ហាក់បីដូចជាមិនសូវសប្បាយចិត្ត និង អាចបាក់ទឹកចិត្តក្នុងការចូលរួមគ្រប់គ្រងធនធានជលផលក្នុងតំបន់នេះនៅពេលអនាគត ។

- ការកើនឡើងនៃចំនួនអ្នកនេសាទ ក៏ដូចជាការបង្កើនចំនួនឧបករណ៍នេសាទរបស់អ្នកនេសាទម្នាក់ៗ ក្នុងតំបន់ជ្រោយប្រស់នាពេលបច្ចុប្បន្ន អាចឈានទៅរកបញ្ហាប្រឈមជាថ្មីឡើងវិញ ចំពោះការគ្រប់គ្រងធនធានជលផលក្នុងតំបន់នេះ ទោះបីជាការអនុវត្តនីគម្រោងបោះបង្គោល និង ប្រអប់នេះកំពុងទទួលបាននូវភាពជោគជ័យក៏ដោយ ។
- ទោះបីជានៅពេលនេះកម្រិតជីវភាពរស់នៅរបស់ប្រជាជនជ្រោយប្រស់ នៅពុំទាន់អាចបង្ហាញឱ្យឃើញច្បាស់ថាត្រូវបានកែលម្អ ឬ លេចធ្លោជាងមុនពេលអនុវត្តគម្រោងក៏ដោយ ។ ពីព្រោះការអនុវត្តនីគម្រោងនេះ ទើបតែមានរយះពេលខ្លីប៉ុណ្ណោះ ។ សម្រាប់ការវាស់វែងលើជីវភាពរស់នៅ ប្រហែលជាត្រូវប្រើរយះពេលវែងជាងនេះ ដើម្បីពិនិត្យមើលភាពប្រែប្រួលដែលត្រូវបានកែលម្អតាមរយះការអនុវត្តនីគម្រោង ។ ទោះបីជាយ៉ាងណាក៏ដោយ ចំណុចដែលគួរឱ្យកត់សំគាល់គឺ បន្ទាប់ពីអនុវត្តគម្រោងមក អ្នកនេសាទដែលប្រើឧបករណ៍ស្របច្បាប់ អាចរក្សាបានលំនឹង និងស្ថេរភាពក្នុងការធ្វើនេសាទក្នុងតំបន់ឈូងជ្រោយប្រស់ ។ ជាពិសេសអ្នកនេសាទក្រីក្រ ស្ត្រី និងកុមារអាចមានលទ្ធភាពគ្រប់គ្រាន់ចំពោះការធ្វើនេសាទក្បែរៗភូមិបាន ។ យ៉ាងណាមិញសុវត្ថិភាពក្នុងការធ្វើនេសាទហាក់ដូចជាមានភាពល្អប្រសើរឡើង ការខូចខាត និងការបាត់បង់ឧបករណ៍នេសាទដោយសកម្មភាពល្មើសនេសាទ ស្ទើរតែត្រូវបានលុបបំបាត់ទាំងស្រុង ។

## ៦. អនុសាសន៍:

- ការអនុវត្តនីគម្រោងនេះតែមួយមុខនៅមិនទាន់គ្រប់គ្រាន់សម្រាប់ការរក្សាលំនឹង និង ចីរភាពធនធានជលផលក្នុងឈូងសមុទ្រជ្រោយប្រស់នៅឡើយ។ ដោយហេតុថាកំណើនអ្នកនេសាទចេះតែកើនឡើងជាបន្តបន្ទាប់ជាមួយនឹងកំណើនចំនួនឧបករណ៍ផងដែរ ។ ដូច្នេះគួរតែមានការកម្រិតកំណត់ ទាំងទំហំ ទាំងបរិមាណ

ឧបករណ៍ និងចំនួនអ្នកនេសាទក្នុងតំបន់នេះ ការបង្កើនទីជម្រកសុវត្ថិភាព កន្លែងអភិរក្ស ឬរដូវបិទនេសាទតាមប្រភេទធនធានជលផលនីមួយៗឱ្យបានជាក់លាក់ ក៏អាចជាមធ្យោបាយមួយជួយរក្សាចីរភាពធនធានជលផលក្នុងតំបន់នេះដែរ ។

- ការអនុវត្តនីគម្រោងធនាគារក្តាមប្រហែលជាឱកាសដ៏ល្អមួយ សម្រាប់ជួយលើកកំពស់ការអប់រំ ការយល់ដឹងរបស់ប្រជានេសាទ ដោយផ្សារភ្ជាប់ទៅនឹងការចូលរួមគ្រប់គ្រងធនធានជលផល ព្រមទាំងជួយបង្កើនឱកាស និង លទ្ធភាពចំពោះពេលវេលាបន្តពូជរបស់ពពួកក្តាមសេះ និង ក្តាមថ្ម ជាមួយនឹងការបង្កើនផលស្តុកក្នុងតំបន់ឆ្នេរជ្រោយប្រស់ថែមទៀតផង ។ កន្លងមកក្នុងឆ្នាំ ២០០៨ នេះ ខ័ណ្ឌរដ្ឋបាលជលផលធ្លាប់បានអនុវត្ត គម្រោងធនាគារក្តាមសេះ ក្នុងតំបន់ជ្រោយប្រស់ជាមួយសហគមន៍ ហើយប្រជាជនហាក់បីមានជំនឿថា បច្ច័យនៃការកើនឡើងនូវផលនេសាទក្តាមសេះឆ្នាំនេះ ប្រហែលមួយចំណែកណានោះ បណ្តាលមកពីការអនុវត្តនីគម្រោងធនាគារក្តាមសេះនេះជាក់ជាមិនខានឡើយ ។
- តំបន់ឈូងជ្រោយប្រស់ គឺជាប្រភពដ៏សំខាន់នៃការកកើត និង រស់នៅរបស់កូនត្រីតុកកែដ៏ច្រើនសន្ធឹកសន្ធាប់ ដែលជាប្រភេទត្រីមានតម្លៃសេដ្ឋកិច្ចខ្ពស់ ។ ដូច្នេះចាំបាច់ត្រូវតែមានវិធានការត្រឹមត្រូវ ជាក់លាក់ បន្ថែមទៀតក្នុងការគ្រប់គ្រង និង ការនេសាទត្រីតុកកែក្នុងតំបន់នេះ ពិសេសកូនត្រីតុកកែតែម្តង ។
- ការពង្រឹងបន្ថែមនូវកិច្ចសហការរវាងស្ថាប័នពាក់ព័ន្ធ និង សហគមន៍ ចំពោះការគ្រប់គ្រងធនធានជលផលក្នុងតំបន់នេះ ។ ពិសេសគួរតែមានវិធានការកម្រិតកំនត់យ៉ាងណា ដើម្បីរក្សាសមធម៌រវាងអ្នកនេសាទខាងក្នុង និង អ្នកខាងក្រៅចំពោះការទទួលបាននូវផលប្រយោជន៍ពីការនេសាទក្នុងតំបន់ឈូងជ្រោយប្រស់នេះ ។ វិធានការសមស្របណាមួយនោះ នឹងអាចជួយជំរុញលើកទឹកចិត្តដល់សហគមន៍ជ្រោយប្រស់ ឱ្យកាន់តែមានឆន្ទៈសកម្មឡើងក្នុងការចូលរួមគ្រប់គ្រងធនធានជលផលក្នុងដែននេសាទសហគមន៍ជ្រោយប្រស់នាពេលអនាគត ។




ផលនេសាទក្តាមសេះពីតំបន់ដែនអេកូឡូស៊ីឈូងសមុទ្រជ្រោយប្រស់




សកម្មភាពនេសាទត្រីកាម៉ុង នៅខេត្តកោះកុង